អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែមិថុនា

លេខ ៣០/២៤ ចេញផ្សាយ ខែមិថុនា ឆ្នាំ២០២៤

## ការរៀបចំផែនការថវិកា



ការរៀបចំផែនការ គឺជាមុខងារនៃការគ្រប់គ្រងដែលទាក់ទងទៅនឹងការកំណត់គោលដៅ និងជាយុទ្ធសាស្រ្តដែលប្រើដើម្បីសម្រេចបាននូវគោលបំណងរបស់ស្ថាប័ន ព្រមទាំងកំណត់នូវវិធីសាស្រ្តដែលប្រើដើម្បីតាមដានត្រួតពិនិត្យការអនុវត្តការងារ។ ដោយឡែកផែនការថវិកា គឺជាឧបករណ៍គ្រប់គ្រងហិរញ្ញវត្ថុដ៏សំខាន់មួយក្នុងការសម្រេចនូវគោលបំណងរបស់ស្ថាប័នដែលទាក់ទងនឹងហិរញ្ញវត្ថុតាមរយៈការបែងចែកធនធានហិរញ្ញវត្ថុ ឬធនធានជាក់ស្តែងឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

ផែនការថវិកា អាចត្រូវបានរៀបចំដោយបុគ្គល ឬដោយជំនួយបច្ចេកទេសពីទីប្រឹក្សាហិរញ្ញវត្ថុ។ ការរៀបចំផែនការថវិកាអាចផ្តោតលើផ្នែកផ្សេងៗជាច្រើន ដូចជាផែនការចូលនិវត្តន៍ ថវិកាអាជីវកម្ម និងផែនការវិនិយោគជាដើម។ ផែនការថវិកា រួមមានផែនការរយៈពេលមធ្យម និងផែនការរយៈពេលខ្លី។

### ១. ផែនការថវិការយៈពេលមធ្យម

ផែនការថវិការយៈពេលមធ្យម គឺជាផែនការយុទ្ធសាស្រ្តថវិកា (៣ឆ្នាំ) ដើម្បីឆ្លុះបញ្ចាំងពីគោលបំណង របស់ស្ថាប័នក្នុងការកសាងកម្មវិធី ឬ/និងយុទ្ធសាស្រ្តអាទិភាពសម្រាប់អនុវត្ត និងកំណត់សូចនាករសម្រាប់វាស់វែងការអនុវត្តនោះ។ ផែនការថវិការយៈពេលមធ្យមទាមទារនូវការកំណត់ធនធានចរន្ត និងធនធានមូលធនដែលត្រូវការ និងការប្រើប្រាស់សម្រាប់ឆ្នាំថវិកា និងពីរឆ្នាំបន្ទាប់របស់ស្ថាប័ន។ ផែនការយុទ្ធសាស្រ្តថវិកានឹងត្រូវធ្វើសមាហរណកម្មជាមួយក្របខ័ណ្ឌចំណាយរយៈពេលមធ្យម សម្រាប់ជាឧបករណ៍ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងជាធាតុចូលដល់ការវិភាជន៍ថវិកាប្រចាំឆ្នាំប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។



### ២. ផែនការថវិការយៈពេលខ្លី

ផែនការថវិការយៈពេលខ្លី គឺជាគម្រោងថវិកាប្រចាំឆ្នាំដែលជាសេចក្តីសង្ខេបនៃចំណូលប៉ាន់ស្មាន និងចំណាយប៉ានស្មានដែលត្រូវបានប្រើប្រាស់ក្នុងរយៈពេលមួយឆ្នាំ។ ដើម្បីរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ស្ថាប័នត្រូវដឹងថាត្រូវផលិតទំនិញ ឬសេវាកម្មក្នុងបរិមាណចំនួនប៉ុន្មាន ត្រូវប្រើប្រាស់ធនធានអ្វីខ្លះ និងក្នុងបរិមាណចំនួនប៉ុន្មានដើម្បីសម្រេចបាននូវការផលិតទំនិញ ឬសេវាកម្មដែលបានគ្រោងទុក។

អត្ថបទ÷ លោកស្រី **អ៊ី សុនីតា**

**ឯកសារយោង÷** ឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុ របស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ**